**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីនៃបណ្តាមិត្តមេគង្គ
# នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ

---

នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីនៃបណ្តាមិត្តមេគង្គ តាមប្រព័ន្ធវីដេអូ ដែលកិច្ចប្រជុំនេះដឹកនាំដោយ **ឯកឧត្តម អេនតូនី ប្លីនខេន** ( Antony Blinken) រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក និងមានការអញ្ជើញចូលរួមរបស់រដ្ឋមន្ត្រីការបរទេស និងតំណាងនៃបណ្តាមិត្តមេគង្គដទៃទៀត។ ដោយឡែក តំណាងជាន់ខ្ពស់នៃអគ្គលេខាធិការដ្ឋានអាស៊ាន ចក្រភពអង់គ្លេស និងឥណ្ឌា ចូលរួមជាអ្នកសង្កេតការណ៍។

កិច្ចប្រជុំរដ្ឋមន្ត្រីនៃបណ្តាមិត្តមេគង្គ ត្រូវបានរៀបចំឡើង ដើម្បីអបអរសាទរខួបគម្រប់១០ឆ្នាំ នៃកិច្ចសហប្រតិបត្តិការនេះ និងស្វាគមន៍ចំពោះលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ដែលក្លាយជាសមាជិកថ្មី ព្រមទាំងដើម្បីបញ្ជាក់សារជាថ្មីអំពីសារៈសំខាន់នៃការចូលរួមរបស់បណ្តាមិត្តមេគង្គក្នុងការដោះស្រាយបញ្ហាប្រឈមឆ្លងដែន គាំទ្រកំណើនប្រកបដោយភាពធន់ និងបរិយាប័ន្ន ក្រោយវិបត្តិកូវីដ-១៩ និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងអនុតំបន់មេគង្គ។ រហូតមកដល់ពេលនេះ សមាជិកនៃបណ្តាមិត្តមេគង្គ បានផ្តល់ការគាំទ្រដល់អនុតំបន់នេះ ក្នុងវិស័យជាអាទិភាពមួយចំនួន រួមមានការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម សុខភាព អាកាសធាតុ បរិស្ថាន ថាមពលទឹក សន្តិសុខស្បៀង ការគ្រប់គ្រងធនធានធម្មជាតិ ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព បំលាស់ប្តូរឌីជីថល និងការអភិវឌ្ឍធនធានមនុស្ស ដោយផ្តោតសំខាន់លើការស្តារឡើងវិញពីជំងឺកូវីដ-១៩ ប្រកបដោយចីរភាព។

ប្រតិភូនៃបណ្តាមិត្តមេគង្គ បានឯកភាពក្នុងការបង្កើនកិច្ចសហប្រតិបត្តិការក្នុងចំណោមសមាជិកជាមួយនឹងយន្តការផ្សេងទៀតដែលមានស្រាប់នៅក្នុងតំបន់មេគង្គ ដើម្បីពង្រឹងការស្តារឡើងវិញ ភាពធន់ និងការអភិវឌ្ឍក្នុងអនុតំបន់ និងបានប្តេជ្ញារួមគ្នាជាថ្មីម្តងទៀត ដើម្បីសម្រេចបាននូវទិសដៅក្នុងរបៀបវារៈឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងដើម្បីអនុវត្តឱ្យបានពេញលេញនូវកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ។

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) [illegible] 22
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ឆ្លៀតឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានបញ្ជាក់ថា កម្ពុជាយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះកិច្ចសហប្រតិបត្តិការនៃបណ្តាមិត្តមេគង្គ ព្រោះកិច្ចសហប្រតិបត្តិការនេះបានដើរតួជាវេទិកាដ៏វិសេសមួយសម្រាប់បណ្តាប្រទេសមេគង្គ និងបណ្តាមិត្តមេគង្គ ដើម្បីជំរុញកិច្ចប្រឹងប្រែងអភិវឌ្ឍជាក់ស្តែង ដោយឈរលើគោលការណ៍ និងគុណតម្លៃរួម។ ដោយយល់ពីសារៈសំខាន់នៃកម្លាំងពលកម្មយុវវ័យក្នុងអនុតំបន់ ក្រោយពេលធូរស្រាលពីការរាតត្បាតជំងឺកូវីដ-១៩ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍ចំពោះការចូលរួមចំណែករបស់បណ្តាមិត្តមេគង្គទាំងអស់ ក្នុងការអភិវឌ្ឍធនធានមនុស្ស ជាពិសេសនៅក្នុងកម្មវិធីពង្រឹងសមត្ថភាពជំនាញបច្ចេកទេស។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់សហរដ្ឋអាមេរិកដែលបានផ្តល់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ តាមរយៈយន្តការកូវ៉ាក់ (COVAX) ដល់បណ្តាប្រទេសក្នុងអនុតំបន់ ដែលក្នុងនោះកម្ពុជាទទួលបានវ៉ាក់សាំងចំនួន១លានដូស ផងដែរ។ នេះឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីការប្តេជ្ញាចិត្តដ៏មុតមាំរបស់សហរដ្ឋអាមេរិក ចំពោះសុខភាពសាធារណៈ និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជននៅក្នុងអនុតំបន់។ យ៉ាងណាក៏ដោយ ជាមួយនឹងរលកថ្មីនៃការរាតត្បាត **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់លើការធ្វើការរួមគ្នា ដើម្បីធានាថាការផ្គត់ផ្គង់វ៉ាក់សាំង និងឧបករណ៍វេជ្ជសាស្ត្រ នៅតែមាន និងប្រកបដោយទំនុកចិត្ត ជាមួយនឹងតម្លៃសមរម្យ។

កិច្ចប្រជុំបានបញ្ចប់ទៅ ជាមួយនឹងការអនុម័តលើសេចក្តីប្រកាសព័ត៌មានរួម។៚

ថ្ងៃសុក្រ ១៣រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០២១